# សមាគមពុទ្ធសាសនិកជនខ្មែរ

## KHMER BUDDHIST FORENING

គ្រីស្ទានសាន់ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥

លេខ៖ ០១៨ ស.ព.ខ/២៥

**សូមគោរពជូន**

**លោក Jonas Gahr Støre នាយករដ្ឋមន្ត្រីនៃប្រទេសន័រវែស**

តាងនាមសមាគមពុទ្ធសាសនិកជនខ្មែរ នៅប្រទេសន័រវែស យើងខ្ញុំសូមជម្រាបជូនលោកនាយករដ្ឋមន្ត្រី ឲ្យបានជ្រាបថា យើងខ្ញុំមានសេចក្ដីព្រួយបារម្ភជាខ្លាំង ចំពោះស្ថានភាពសង្គ្រាមរវាងកម្ពុជា និងថៃ មិនទាន់ត្រូវបានបញ្ចប់នៅឡើយ ទោះបីជាមានកិច្ចព្រមព្រៀងបទឈប់បាញ់ តាំងពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ហើយក្ដី។ ប៉ុន្តែភាគីយោធាថៃ នៅបន្តរំកិលព្រំដែនឈ្លាន ពានចូលក្នុងដែនអធិបតេយ្យរបស់កម្ពុជា តាមរយៈការដាក់រាយបន្លាលួស ការឈូសឆាយផ្លូវ ការប្រើជំពាមកៅស៊ូបាញ់មកលើភាគីកម្ពុជា និងការរឹបអូសយកលំនៅឋានរបស់ពលរដ្ឋខ្មែរនៅក្បែរតំបន់ព្រំដែន ក្នុងនោះមានខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តពោធិសាត់។ ជាងនេះទៀត យោធាថៃបន្តឃុំខ្លួនយោធាខ្មែរ ១៨ នាក់ជាចំណាប់ខ្មាំង តាំងពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ មិនទាន់ដោះលែងនៅឡើយ។ ទង្វើរបស់ភាគីថៃទាំងនេះ គឺជាការរំលោភបទឈប់បាញ់ និងច្បាប់អន្តជាតិនានា។

ផលប៉ះពាល់នៃសង្គ្រាមនេះ បណ្ដាលឲ្យជនស៊ីវិលកម្ពុជា ជាង ១៣៤.០០០នាក់ ក្លាយជាជនភៀសសឹក ជាមួយការឈឺចាប់ឥតគណនា ដោយសារការបាត់បង់ផ្ទះសម្បែង សាលារៀន មុខរបររកស៊ី និងមណ្ឌលសុខភាព ជាដើម។ សាលារៀនប្រមាណ ៦០០ ត្រូវបានបិទទ្វារក្នុងខេត្តចំនួន ៥ នៅក្នុងនោះមានសិស្សនិស្សិតប្រមាណ ១៥.០០០នាក់ ត្រូវបានផ្អាកការសិក្សា។ ជនភៀសសឹកទាំងអស់ រួមទាំងស្ត្រី និងកុមារ កំពុងជួបការលំបាក ពួកគាត់ត្រូវការជំនួយអាហារូបត្ថម្ភ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ។ ជាមួយគ្នានេះ ពលករខ្មែរប្រមាណ ១.០០០.០០០នាក់ បានវិលត្រឡប់ពីប្រទេសថៃ ក្នុងអំឡុងពេលសង្គ្រាម នេះ។

**លោកនាយករដ្ឋមន្ត្រីជាទីគោរព !**

យើងខ្ញុំសូមស្នើលោកនាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលនៃប្រទេសន័រវែស ជួយអន្តរាគមន៍តាមមធ្យោបាយការទូត ដើម្បីបញ្ឈប់សង្គ្រាមរវាងកម្ពុជា-ថៃ បញ្ចៀសសោកនាដកម្ម និងការឈឺចាប់នានា ដល់ពលរដ្ឋនៃប្រទេសទាំងពីរ។

សូមលោកនាយករដ្ឋមន្ត្រី ជួយជំរុញឲ្យភាគីថៃ ត្រូវដោះលែងយោធាទាំង ១៨នាក់, ផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះ និងផ្ដល់ជំនួយមនុស្សធម៌ដល់ជនភៀសសឹកកម្ពុជា។

**ដោយក្ដីគោរពរាប់អាន**

(ហត្ថលេខា និងត្រា)

**ម៉ែន ណាត**

**ប្រធានសមាគមពុទ្ធសាសនិកជនខ្មែរ**

---

Address: Senterveien 54, Apartment 112, 4790 Lillesand, Norway | Website:Khmer Buddhist Society Norway
Organization No: 980 411 931